# ការប្រជុំយុវនារីទូទៅ

ថ្ងៃទី 29 ខែ មិនា ឆ្នាំ 2008

## ឈរជាសាក្សី

ស៊ូសាន ដុបលយូ ថែនណឺរសាន
ជាប្រធានយុវនារីទូទៅ

*អ្នក...អាចឈរជាសាក្សីនៃព្រះ ដោយការចិញ្ចឹមបីបាច់វិញ្ញាណនៃសេចក្ដីជំនឿ សេចក្ដីស្រឡាញ់ សេចក្ដីសុខ សាន្ត និងទីបន្ទាល់នៅក្នុងផ្ទះរបស់អ្នក ។*

ខណៈពេលខ្ញុំឈរនៅលើវេទិកានេះ ខ្ញុំស្រម៉ៃមើលមុខយុវនារីទាំងអស់ជុំវិញពិភពលោក ។ ឱខ្ញុំស្រឡាញ់អ្នកណាស់! ខ្ញុំពេញចិត្តនឹងសន្យាចំពោះអ្នកជាពិសេសថា យើងនឹង " ឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និងគ្រប់សេចក្ដី និងគ្រប់ទីកន្លែង" ។ 1 តើយើងអាចធ្វើដូច្នេះដោយរបៀបណា? ខណៈពេលខ្ញុំនិយាយ ខ្ញុំសូមអធិស្ឋានថា ព្រះវិញ្ញាណនឹងដឹកនាំយើង ហើយថ្លែងទីបន្ទាល់មកកាន់យើងម្នាក់ៗ អំពីរបៀបដែលយើងអាចឈរជាសាក្សីចំពោះព្រះ ។

នៅពេលកូនរបស់យើងជាអ្នកផ្សព្វផ្សាយសាសនា ពួកគេបានរៀនថា ពេលយើងឈរធ្វើជាសាក្សីអំពីព្រះយេស៊ូវគ្រីស្ទ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ពីទីបន្ទាល់នោះ ។ កូនស្រីម្នាក់របស់យើងមានអ្នករៀនថ្មីម្នាក់ដ៏ល្អវិសេសឈ្មោះ ជេលី ។ ក្មេងស្រីមជ្ឈឹមវ័យម្នាក់នេះ គោរពតាមអ្វីគ្រប់យ៉ាងដែលបានបង្រៀនដល់នាង ទោះបីជាពិបាកយ៉ាងណាក្ដី ។ នាងជានិស្សិតម្នាក់ដែលជួបប្រទះនឹងភាពស្មុគ្រស្មាញផ្នែកហិរញ្ញវត្ថុ ប៉ុន្តែនាងបានចាប់ផ្ដើមបង់ដង្វាយមួយភាគក្នុងដប់របស់នាង ពេលដែលនាងបានរៀនអំពីច្បាប់នោះ ។ ការងារក្រៅម៉ោងរបស់នាង តំរូវឱ្យនាងធ្វើការនៅថ្ងៃអាទិត្យ ប៉ុន្តែនាងមានសេចក្ដីក្លាហានគ្រប់គ្រាន់ ក្នុងការសុំឱ្យនិយោជករបស់នាង ផ្លាស់ម៉ោងរបស់នាងឱ្យធ្វើការនៅថ្ងៃផ្សេង ដើម្បីនាងអាចចូលរួមក្នុងការប្រជុំសាក្រាម៉ង់ ។

ថ្វីបើនាងឧស្សាហ៍ព្យាយាមក្ដី ជេលី នៅតែមិនមានទីបន្ទាល់រឹងមាំអំពីព្រះគម្ពីរមរមន ។ កូនស្រីរបស់យើង និងដៃគូនាងបានដឹងថា នាងត្រូវការសាក្សីមកពីព្រះវិញ្ញាណបញ្ជាក់ពីសេចក្ដីពិតរបស់ព្រះគម្ពីរ ដូច្នេះពួកគេបានរៀបចំមេរៀនមួយសំរាប់នាងអំពីព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលពួកគេរៀបចំ ពួកគេមានអារម្មណ៍ថាដូចជាមិនត្រូវទេ ។ នៅពេលពួកគេអធិស្ឋានអំពីរឿងនេះ ពួកគេមានទទួលអារម្មណ៍ថា ឱ្យបែរទៅទិសដៅផ្សេង ឱ្យផ្ដល់មេរៀនមួយអំពីព្រះយេស៊ូវគ្រីស្ទ ជំនួសវិញ ។

ពេលការណាត់ជួបមកដល់ អ្នកផ្សព្វផ្សាយសាសនាពីររូបនេះបានចាប់ផ្ដើមបង្រៀន ជេលី អំពីព្រះយេស៊ូវគ្រីស្ទ ។ ទឹកភ្នែកបានចាប់ផ្ដើមហូរលើថ្ពាល់របស់នាង ។ នាងនៅបន្តសួរទៀតថា: "តើអារម្មណ៍អ្វីដែលខ្ញុំកំពុងទទួលនេះ?" បន្ទាប់មកពួកគេបានថ្លែងជាសាក្សីចំពោះនាងថា នោះគឺជាព្រះវិញ្ញាណ ។ ពិតណាស់អ្វីដែលពួកគេចង់ឱ្យកើតឡើងនោះវាបានកើតឡើងមែន ។ នៅពេលនោះកូនស្រីរបស់យើងបានចាំថា តួនាទីមួយដ៏ចម្បងរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្នកថ្លែងទីបន្ទាល់របស់ព្រះគ្រីស្ទ ។ ព្រះយេស៊ូវផ្ទាល់បាន ថ្លែងទីបន្ទាល់ថា: "តែព្រះដ៏ជាជំនួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ...

នឹងធ្វើទីបន្ទាល់ពីខ្ញុំ"។2 កូនស្រីយើងចាប់ផ្តើមដឹងថាពេលនាង ឈរជាសាក្សីចំពោះព្រះយេស៊ូវ គ្រីស្ទ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ពីរឿងនោះ។ យើងក៏ដូចគ្នាផងដែរអាចឈរជាសាក្សី "ហើយយើងនិយាយ អំពីព្រះគ្រីស្ទ ហើយអរ-រីករាយក្នុងព្រះគ្រីស្ទ យើងផ្សាយអំពីព្រះគ្រីស្ទ" ហើយក្រឡេកមើលទៅទ្រង់ជាប្រភពសំរាប់ "ផ្តាច់បាប [របស់យើង] "។3

ស្តេចសុចរិតបេនយ៉ាមីន នៅក្នុងព្រះគម្ពីរមរមនបានប្រមូលផ្តុំរាស្ត្រទ្រង់ជួបជុំគ្នានៅព្រះវិហារបរិសុទ្ធ ដើម្បីឱ្យទ្រង់អាចមានបន្ទូល និងផ្សព្វផ្សាយអំពីព្រះគ្រីស្ទ។ ទ្រង់បានបង្រៀនរាស្ត្រទ្រង់អំពីសេចក្តីល្អរបស់ព្រះអម្ចាស់ ព្រះចេស្តាប្រាជ្ញា ការអត់ធ្មត់របស់ទ្រង់ និងលើគ្រប់ទាំងអ្វីៗទាំងអស់គឺដង្វាយធួនរបស់ទ្រង់។ នៅពេលទ្រង់បានឈរជាសាក្សី ព្រះវិញ្ញាណបានថ្លែងទីបន្ទាល់ដល់ពួកគេថាព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះ ដូចជា ដេលី ដែរ។ បន្ទាប់មក ស្តេចបេនយ៉ាមីន បានដាស់តឿនរាស្ត្រទ្រង់ឱ្យឈរដោយខ្ជាប់ខ្ជួននៅក្នុងជំនឿរបស់ពួកគេទៅលើព្រះគ្រីស្ទ។ រាស្ត្រទាំងអស់បានស្រែកឡើងព្រមគ្នាថា:

"យើងជឿតាមពាក្យទាំងអស់ដែលទ្រង់មានបន្ទូលមកកាន់ពួកយើង...ពីព្រោះតែព្រះវិញ្ញាណនៃព្រះអម្ចាស់... ដែលបាននាំមកនូវការផ្លាស់ប្តូរយ៉ាងធំដល់ពួកយើង ឬក៏នៅក្នុងចិត្តយើងខ្ញុំ ដែលធ្វើឱ្យយើងខ្ញុំពុំមាន បំណងនឹងប្រព្រឹត្តអំពើទុច្ចរិតទៀតឡើយ ប៉ុន្តែចង់ប្រព្រឹត្តល្អជានិច្ចវិញ...។

"ហើយយើងខ្ញុំព្រមចូលទៅក្នុងសេចក្តីសញ្ញា ជាមួយនឹងព្រះរបស់ពួកយើង ... ដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ចំពោះអ្វីៗទាំងអស់"។4

រាស្ត្ររបស់ស្តេចបេនយ៉ាមីន បានចុះសេចក្តីសញ្ញា ដើម្បីគោរពតាមព្រះបញ្ញត្តិទ្រង់ ក៏ដូចជាយើងម្នាក់ៗផងដែរ។ នៅពេលអ្នករក្សាសេចក្តីសញ្ញានោះ នោះអ្នកនឹងឈរជាសាក្សីចំពោះមិត្តភក្តិរបស់អ្នក។ ថ្មីៗនេះ កូនៗរបស់ខ្ញុំ និងដៃគូពួកគេបានចងចាំពីពេលវេលាដែលពួកគេឆ្លងកាត់ នៅពេលដែលបានក្រោកឈរដើម្បីតម្លៃយ៉ាងត្រឹមត្រូវក្នុងពេលដែលប្រឈមមុខនឹងការគាបសង្កត់ពីមិត្តភក្តិ។ ម្នាក់មិនបានចូលរួមក្នុងក្រុមរាំលើកទឹកចិត្តនៅថ្ងៃអាទិត្យម្នាក់ទៀតបានប្រាប់ដល់និយោជិករបស់គាត់ថា គាត់មិនអាចធ្វើការនៅថ្ងៃឈប់សំរាកបានទេ។ ម្នាក់ទៀតបានបដិសេធមិនមើលកុនអាសគ្រាម នៅផ្ទះរបស់មិត្តភក្តិនៅពេលដែលគាត់មានអាយុតែដប់មួយឆ្នាំ ម្នាក់ទៀតបានបដិសេធនឹងមិត្តរួមថ្នាក់ថាមិនមើលទស្សនាវដ្តីអាសគ្រាម។ ទាំងពីនាក់ត្រូវបានគេបណ្តេញចេញពីសង្គម ចាប់តាំងពីពេលនោះមក។ កូនម្នាក់ទៀតបដិសេធក្នុងការប្រើពាក្យអសុរស ជេរប្រមាថ បាទផ្សា នៅក្នុងបរិយាកាសការងាររបស់នាង។ ម្នាក់បានបដិសេធមិនផឹកស្រាដែលមិត្តរបស់គាត់បានលួចពីក្នុងទូរដែលឪពុកម្តាយវាបានចាក់សោរ។ ម្នាក់ទៀតគឺជាពួកបរិសុទ្ធតែម្នាក់គត់នៅក្នុងថ្នាក់របស់នាងដែលបានក្រោកឈរឡើងធ្វើបទបង្ហាញអំពីមេរៀនភាសាអង់គ្លេស ហើយដែលបានបញ្ចប់ដោយការឆ្លើយសំណួរនៅក្នុងព្រះគម្ពីរមរមន។ កូនៗដែលរៀបការហើយរបស់យើង បានបន្តបង្កើតកូនចៅចូលក្នុងលោកិយដែលពេញដោយការរិះគន់នេះ។

ក្នុងខណៈពេលនេះពួកគេមានអារម្មណ៍ឯកកោរ ប៉ុន្តែនៅពេលពួកគេក្រោយឈរឡើងជាសាក្សី ពួកគេបានទទួលអារម្មណ៍ជាដៃគូ និងការជួយគាំទ្រពីវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេក៏បានត្រៀមខ្លួនសំរាប់ពរជ័យដែលបានមកពីការគោរពតាមបទបញ្ញត្តិរបស់ព្រះ។ ទ្រង់បានសន្យានឹងយើងថា: "កុំឱ្យភ័យខ្លាចឡើយ ត្បិតអញនៅជាមួយនឹងឯងកុំឱ្យស្រយុតចិត្តឱ្យសោះ ពីព្រោះអញជាព្រះនៃឯង អញនឹងចំរើនកម្លាំងដល់ឯង អើអញនឹងជួយឯង អើអញនឹងទ្រឯង

ដោយដៃស្តាំដ៏សុចរិតរបស់អញ"។5

កូន១របស់ខ្ញុំគឺពិតជាបានតោងជាប់នឹងព្រះហស្ថរបស់ទ្រង់ ពេលពួកគេថ្លែងទីបន្ទាល់អំពីព្រះ ដោយឈរយ៉ាងខ្ជាប់ខ្ជួនក្នុងការរក្សាតាមបទបញ្ញត្តិរបស់ទ្រង់។ ខ្ញុំបានទទួលពរជ័យ និងរឹងមាំដោយសារគំរូរបស់ពួកគេ។

ពេលអ្នកឈរជាសាក្សីក្នុងគេហដ្ឋានរបស់អ្នក នោះអ្នកនឹងពង្រឹងគ្រួសារអ្នក។ ជាញឹកញាប់យើងបានគិតអំពីឃ្លានៅក្នុងបាវចនាយុវនារីថា: "ដើម្បីពង្រឹងគេហដ្ឋាន និងគ្រួសារ" 6 ដែលមិនត្រឹមតែអនុវត្តចំពោះទំនួលខុសត្រូវនាពេលអនាគតសំរាប់យុវនារីដែលជាភរិយា និងជាម្តាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏អនុវត្តចំពោះទំនួលខុសត្រូវរបស់ពួកគេក្នុងនាមជាបុត្រធីតា និងជាបងប្អូនស្រី នៅក្នុងគេហដ្ឋានរបស់ពួកគេទីនេះ និងឥឡូវនេះផងដែរ។

ម្តាយបង្កើតរបស់ខ្ញុំបានជួយពង្រឹងគេហដ្ឋាន និងគ្រួសារក្នុងយុវវ័យរបស់គាត់។ គាត់ជាកូនច្បងក្នុងគ្រួសារដែលមិនសូវសកម្ម ប៉ុន្តែគាត់បានកើតមកជាមួយអំណោយទាននៃសេចក្តីជំនឿ។ គាត់ទៅថ្នាក់កុមារ និងសកម្មភាពម៉ូឆល ដោយខ្លួនឯង។ គាត់មានគុណសម្បត្តិគ្រប់គ្រាន់សំរាប់អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ មុនឪពុកម្តាយរបស់គាត់អាចទៅ។ គាត់ក្លាយជាគំរូនៃសេចក្តីសុចរិត ជាសាក្សីខ្ជាប់ខ្ជួនដែលគំរូរបស់គាត់បានជួយពង្រឹងឪពុកម្តាយ និងបងប្អូនទាំងឡាយ។ យុវនារីទាំងឡាយក៏អាចឈរដូចគ្នា ធ្វើជាសាក្សីចំពោះព្រះ ចិញ្ចឹមបីបាច់ដោយវិញ្ញាណនៃសេចក្តីជំនឿក្តីស្រឡាញ់ ភាពសុខសាន្ត និងទីបន្ទាល់ នៅក្នុងគេហដ្ឋានអ្នកឥឡូវនេះ រៀបចំខ្លួនអ្នកឱ្យធ្វើដូចគ្នា នៅពេលអ្នកស្ថាបនាអនាគតគេហដ្ឋានរបស់អ្នក។ ខ្ញុំគឺជាផលិតផលនៃការក្រោកឈររបស់ស្ត្រីសុចរិតម្នាក់ ដែល " ខ្ជាប់ខ្ជួន ហើយនឹងនរ គឺពោរពេញទៅដោយអំពើល្អជានិច្ច"។7

យើងក៏ធ្វើជាសាក្សីចំពោះព្រះយេស៊ូវគ្រីស្ទ ផងដែរនៅពេលដែលយើងរីករាយក្នុងទ្រង់។ ដូចជាអ្វីដែលរាស្ត្ររបស់ស្តេចបេនយ៉ាមីន បានរៀនបន្ថែមទៀតអំពីព្រះយេស៊ូវ ពួកគេនិយាយថា: "ការណ៏ទាំងឡាយដែលស្តេចរបស់យើងខ្ញុំ [មាន] បន្ទូលមកកាន់ពួកយើងដែលបាននាំមកដល់យើងខ្ញុំនូវការចេះដឹងដ៏ធំនេះ ម៉្លោះហើយយើងខ្ញុំអររីករាយដោយសេចក្តីអំណរដ៏មហិមា"។ 8 នៅពេលដែលយើងរីករាយក្នុងព្រះអង្គសង្គ្រោះ នោះយើងចងចាំទ្រង់ និងពរជ័យដ៏មហិមាចំពោះយើង។ យើងឈរជាសាក្សី ពេលយើងបង្ហាញគារវភាព និងក្តីអំណរដ៏ភ្លឺថែងចាំង។ ដូចជាអ្វីដែលយុវនារីបានច្រៀងបើកការប្រជុំនេះថា: "តើអ្នកមិនបានឃើញពីក្តីត្រូវការដែលបានប្រទានឱ្យចំពោះអ្វីដែលទ្រង់បានតែងតាំងទេឬ?" 9

ថ្មី១នេះខ្ញុំបានរៀនអំពីយុវនារីក្លាហានពីរនាក់ដែលបានរស់នៅតាមបទបញ្ញត្តិ និងមានពន្លឺនៃសេចក្តីអំណរនៃដំណឹងល្អដែលបានក្រោកឈរឡើងជាសាក្សីនៃព្រះ។ នេះគឺជាដំណើររឿងដែលបានរៀបរាប់ ដោយអ្នកផ្សព្វផ្សាយសាសនារៀមច្បងម្នាក់នៅ MTC។

គាត់បាននិយាយថាកាលពីប៉ុន្មានឆ្នាំមុន នាថ្ងៃមួយគាត់បាននៅក្នុងផ្ទះបោកអ៊ុតសំលៀកបំពាក់ មើលទូរទស្សន៏កម្មវិធី ស៊ុបអូប៉ារ៉ា ហើយកំពុងជក់បារី នៅពេលនោះមានសម្លេងគោះទ្វារ។ ពេលគាត់បើកទ្វារមានបុរសពីរនាក់ពាក់អាវពណ៌ស និងក្រវ៉ាត់ក ហើយម្នាក់ក្នុងចំណោមពួកគេបានណែនាំខ្លួនថាគាត់ជាប៊ីស្សពរបស់គាត់។ លោកបាននិយាយថា នៅពេលលោកកំពុងអធិស្ឋាន លោកក៏មានអារម្មណ៏នៃការបំផុសគំនិតថា សុំឱ្យនាងបង្រៀនយុវនារី។ នាងបាននិយាយប្រាប់គាត់ថា នាងបានជ្រមុជទឹកនៅអាយុដប់ឆ្នាំ ប៉ុន្តែមិនដែលសកម្មទេ។ គាត់មើលទៅហាក់បីដូចជាមិនរុញរាឡើយ នៅពេលគាត់បង្ហាញសៀវភៅណែនាំសិក្សា ហើយពន្យល់ពីទីកន្លែងដែលពួកគេប្រជុំនៅយប់ថ្ងៃពុធ។ បន្ទាប់មកនាងបានគូស

បញ្ជាក់ថា: "ខ្ញុំមិនអាចបង្រៀនក្មេងអាយុ 16 ឆ្នាំបានទេ ខ្ញុំអសកម្ម ហើយក្រៅពីនោះខ្ញុំបានជក់បារី"។ បន្ទាប់មកលោកបាននិយាយថា "អ្នកមិនអសកម្មទៀតទេ ហើយអ្នកមានពេលរហូតដល់ថ្ងៃពុធដើម្បីឈប់ជក់បារី" បន្ទាប់មកគាត់បានចាកចេញ។ នាងនិយាយថា: "ខ្ញុំនៅចាំពីការស្រែកខ្លាំងៗដោយកំហឹង ប៉ុន្តែខ្ញុំមិនអាចទប់ទល់ នឹងការបន្ទាន់ដើម្បីអានសៀវភៅណែនាំសិក្សានោះបានទេ។ ជាការពិតណាស់ខ្ញុំចង់ដឹងខ្លាំងណាស់ ខ្ញុំបានអានវាពីដើមដល់ចប់ ហើយចងចាំគ្រប់ពាក្យទាំងអស់ក្នុងមេរៀន។

"រហូតដល់ថ្ងៃពុធ ខ្ញុំនៅតែមិនចង់ទៅទេ ប៉ុន្តែខ្ញុំបែរជាបើឡានទៅសាសនាចក្រដោយមិនដឹងខ្លួនទាំងភ័យស្ទើរស្លាប់។ ពីមុនខ្ញុំមិនធ្លាប់ខ្លាចអ្វីដូច្នេះទេ។ ខ្ញុំបានធំឡើងក្នុងតំបន់ក្រីក្រ ថែទាំខ្លួនឯង ហើយជួយសង្គ្រោះឪពុកចេញពីមន្ទីរអប់រំអ្នកប្រមឹក។ ហើយរំពេចនោះខ្ញុំនៅទីនេះក្នុងសកម្មភាពម៉ូឆល ដោយចាប់ផ្តើមណែនាំខ្លួនថាជាអ្នកផ្តល់ដំបូន្មានថ្នាក់ ឡូរ៉ល ថ្មី។ ខ្ញុំបានអង្គុយនៅពីមុខយុវនារីពីរនាក់ បង្រៀនមេរៀន តាមសៀវភៅមួយពាក្យមួយពាក្យ សូម្បីតែផ្នែកដែលនិយាយថា: ‘ឥឡូវនេះខ្ញុំសួរពួកគេ...’ ខ្ញុំបានចាកចេញភ្លាមបន្ទាប់ពីបង្រៀនមេរៀនហើយ ហើយយំតាមផ្លូវរហូតដល់ផ្ទះ។

"ពីរបីថ្ងៃក្រោយមក មានសម្លេងគោះទ្វាទៀត ហើយខ្ញុំបានគិតថា: ‘ល្អហើយ ប៊ីស្សពមកយកសៀវភៅណែ-នាំសិក្សាគាត់ទៅវិញ’ ។ ខ្ញុំបានបើកទ្វារ ហើយអ្នកដែលឈរនៅទីនោះ គឺយុវនារីគួរឱ្យស្រឡាញ់ពីរនាក់ ម្នាក់កាន់ផ្កា ហើយម្នាក់ទៀតកាន់នំយុកគី។ ពួកគេបានអញ្ជើញខ្ញុំឱ្យទៅសាសនាចក្រជាមួយពួកគេនៅថ្ងៃអាទិត្យ ខ្ញុំបានទៅ។ ខ្ញុំចូលចិត្តក្មេងស្រីទាំងនោះ។ ពួកគេបានចាប់ផ្តើមបង្រៀនខ្ញុំអំពីសាសនាចក្រ វួដ និងថ្នាក់រៀន។ ពួកគេបង្រៀនខ្ញុំឱ្យចេះដេរ អានព្រះគម្ពីរ និងចេះញញឹម។

"យើងបានចាប់ផ្តើមបង្រៀនក្មេងស្រីផ្សេងទៀតនៅក្នុងថ្នាក់ដែលមិនមក។ យើងបានបង្រៀនពួកគេ នៅពេលយើងរកគេឃើញ---នៅក្នុងឡាន ច្រកចូលផ្ទះ និងរានហាល។ ក្នុងរយៈពេលប្រាំមួយខែ មានយុវនារីដប់ប្រាំមួយនាក់បានត្រឡប់មកវិញ ហើយក្នុងរយៈពេលមួយឆ្នាំក្មេងស្រីដប់ប្រាំមួយនាក់បានសកម្មឡើងវិញ។ យើងសើចយំជាមួយគ្នា។ យើងរៀនអធិស្ឋានជាមួយគ្នា សិក្សាដំណឹងល្អជាមួយគ្នា និងបំរើអ្នកដទៃជាមួយគ្នា។" 10

ក្មេងស្រីក្លាហានទាំងពីរនាក់នោះបានឈរជាសាក្សីសំរាប់សេចក្តីពិត និងសេចក្តីសុចរិត ហើយនិងអំពើល្អ និងក្តីអំណរនៅក្នុងដំណឹងល្អ។

ខណៈដែលខ្ញុំត្រូវបានហៅឱ្យធ្វើជាប្រធានយុវនារីទូទៅ ខ្ញុំបានទទួលពរជ័យនៅក្នុងពិធីញែកចេញរបស់ខ្ញុំថា សេចក្តីជំនឿរបស់ខ្ញុំទៅលើព្រះយេស៊ូវគ្រីស្ទនិងរឹងមាំតាមរយៈការបំរើរបស់ខ្ញុំ។ ខ្ញុំបាននៅជុំវិញស្ត្រីក្លាហានទាំងឡាយទាំងពីប្រឹក្សា និងគណៈកម្មការរបស់ខ្ញុំ គណៈប្រធានអង្គការជំនួយផ្សេងទៀត និងជនមុនៗដែលគួរឱ្យគោរពរបស់ខ្ញុំព្រមទាំងអតីតប្រធានយុវនារីទូទៅ។ ពួកគេបានក្រោកឈរធ្វើជាសាក្សីរបស់ព្រះយេស៊ូវ គ្រីស្ទ ដោយគំរូល្អ និងការបំរើមិនអាត្មានិយមនៅក្នុងជីវិតពួកគេ។

ដោយសារភាពរឹងមាំមកពីស្ត្រីទាំងនេះ សមាជិកគ្រួសាររបស់ខ្ញុំ និងភាពខ្ជាប់ខ្ជួន ហើយនឹងនររបស់យុវនារី និងអ្នកដឹកនាំជុំវិញពិភពលោក ខ្ញុំមានអារម្មណ៍ថា: "ដែលមានស្ទរបន្ទាល់មួយហ្វូងធំម្លេះ"។ ចំនុចនេះបានជួយឱ្យខ្ញុំ "រត់នៅក្នុងទីប្រណាំងនៅមុខ [យើង] ដោយអំណត់ ទាំងរំពឹងមើលដល់ព្រះយេស៊ូវ ដ៏ជាមេផ្តើម ហើយជាមេសំរេចសេចក្តីជំនឿរបស់យើង"។11

សេចក្តីសន្យានៃការបង្កើនសេចក្តីជំនឿលើព្រះយេស៊ូវ គ្រីស្ទរបស់ខ្ញុំនៅក្នុងពិធីញែកចេញត្រូវបានបំពេញខណៈពេលដែលខ្ញុំមានឱកាសឈរជាសាក្សីចំពោះទ្រង់ជារៀងរាល់ថ្ងៃ និងគ្រប់ទីកន្លែង ។ ខ្ញុំបានថ្លែងអំពីទ្រង់ ប្រកាសអំពីទ្រង់ និងរីករាយនៅក្នុងទ្រង់ ។ ពេលខ្ញុំមានអារម្មណ៍ថាពាក្យសំដីរបស់ខ្ញុំមិនល្អគ្រប់គ្រាន់ នោះខ្ញុំត្រូវបានទទួលការបញ្ជាក់ពីព្រះវិញ្ញាណរបស់ទ្រង់ ។ ពេលខ្ញុំមានអារម្មណ៍ភ័យខ្លាច ឬមិនល្អគ្រប់គ្រាន់ ខ្ញុំត្រូវបានពង្រឹងនិងលើកឡើងដោយព្រះហស្ដអទិទេពរបស់ទ្រង់ ។ ខ្ញុំដឹងថាទ្រង់នឹងប្រទានពរដល់យើងម្នាក់ៗ នៅពេលយើងឈរជាសាក្សី ។ ទ្រង់នឹង "គ្មានថ្ងៃបោះបង់ចោល" 12 យើងឡើយ ។ ចូរយើងឆ្ពោះទៅមុខដោយខ្ជាប់ខ្ជួនក្នុងសេចក្តីជំនឿលើព្រះគ្រីស្ទ ឈរជាសាក្សីដល់ទ្រង់គ្រប់ពេល និងគ្រប់សេចក្តី និងគ្រប់ទីកន្លែង នេះជាការអធិស្ឋានរបស់ខ្ញុំ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ម៉ូសាយ 18:9 ។

2. យ៉ូហាន 14:26; 15:26 ។

3. នីហ្វៃទី 2 25:26 ។

4. ម៉ូសាយ 5:2, 5 ។

5. អេសាយ 41:10 ។

6. "បាវចនារបស់យុវនារី" *ការពង្រីកខ្លួនរបស់យុវនារី* (កូនសៀវភៅ ឆ្នាំ 2001), 5 ។

7. ម៉ូសាយ 5:15 ។

8. ម៉ូសាយ 5:4 ។

9. *ទំនុកដំកើងព្រះ #72* "Praise to the Lord, the Almighty" ។

10. For another account of this experience សូមមើល: Joan Atkinson "មិនមែនខ្ញុំទេ ខ្ញុំជក់ហើយផឹក" *Tambuli* ខែកុម្ភៈ ឆ្នាំ 1989, 19--20 ។

11. ហេព្រើរ 12:1-2

12. ទំនុកដំកើងព្រះ #6 "គ្រឹះដ៏មាំមួន" ។